អធិរាជ អង្គមែនរ៉េត៍ ស្តេចសម្លឹងនាងដោយងឿងឆ្ងល់។

មេរូបានយំប្រាប់ទៀតថា៖

«ផ្ទៃទន្លេពណ៌ខ្មៅបានស្រែកឡូឡាឡើងថា ខ្ញុំនេះមិនអាចក្លាយទៅជាប្រពន្ធរបស់អ្នកជារៀងរហូត ថែមទាំងមិនអាចចូលទៅក្នុងរាជប្រាសាទជាអតីតរាជវាំងនោះជាមួយអ្នកជារៀងតទៅ!»

ស្តេចអង្គុយចុះជ្រប់ព្រះភក្ត្រគិតសញ្ជឹងពីហេតុភេទនៃសុបិនចម្លែករបស់ពៅពុំងា ម្តងម្កាលទ្រង់សម្លឹងមើលភរិយានេះពីលើដល់ក្រោមព្រោះក្តីងឿងឆ្ងល់ជាពន់ពេកអំពីហេតុភេទដែលនាងមិនអាចទៅតាមទ្រង់។

ពេលវេលាកន្លងទៅ ស្តេចគិតមិនយល់អ្វីក៏ប្រឹងនិយាយលួងលោមថា៖

«ចូរនាងកុំភ័យអ្វីស្ងួនពុំងានៃបង! រៀមសច្ចាថាបងនឹងរកគ្រប់មធ្យោបាយ ទោះបីជាត្រូវបង្វិលចក្រវាលទាំងមូល ក៏នឹងនាំប្អូនស្រីមករស់ក្នុងប្រាសាទចាស់ជាមួយបងជាគ្នារហូតតទៅដល់តែបានសម្រេច!»

ប្តីប្រពន្ធទាំងពីរបានយល់ចិត្តគ្នាដោយការក្រសោបក្រសាលក្នុងរង្វង់ដៃ ហើយមេរូបាននិយាយឡើងថា ៖

«អ្នកគួរដឹងហើយថា ខ្ញុំមានចិត្តស្នេហាចំពោះអ្នកកម្រិតណា ហើយខ្ញុំមិនអាចរស់នៅគ្មានអ្នកបាននៅទេបើថ្ងៃណាមួយអ្នកចាកចេញពីខ្ញុំទៅ ឬក៏អ្នកនាំនារីផ្សេងទៅកាន់ប្រាសាទនោះខ្ញុំច្បាស់ជាក្លាយជាមនុស្សឆ្កួតនៅក្នុងលោកនេះ!»

ភ្លាមៗនោះគ្រប់យ៉ាងញ័ររញ្ជួយ។ តំណក់ទឹកជាច្រើនចាប់ផ្តើមជ្រៀតចេញពីជញ្ជាំងទាំងអស់នៅក្នុងផ្ទះ។ មេរូត្រូវស្រឡាំងកាំងខណៈទឹកចាប់ផ្តើមលិចឡើងស្រីតៗដូចកាលដែលនាងធ្លាប់គេងនៅសាឡុងត្រូវលិចលង់ដែរ។

ឃើញហេតុភេទចម្លែកដូច្នេះដែរ ធ្វើឲ្យស្តេចអធិរាជទៅជាតាមដានដោយគ្មានពាក្យស្តីស្រឡាំងកាំង ខណៈពេលមានសំឡេងមនុស្សស្រីស្រែកយំល្វើយៗពីក្នុងទឹកមកប្រាប់ថា៖

«មិនត្រាវ៉ារីនេះហើយជាអ្នកធ្វើឲ្យអូនក្លាយទៅជាទឹក! សាវ៉ាឌី ស្វាមីនៅចាំដែរទេ? យើងបានស្បថនឹងគ្នាថា មនុស្សស្រីណាក្តីដែលមិនមែនជាអូន វាមិនអាចគន្លងគាថាទ្វារជ័យនៃប្រាង្គរាជវាំង ចូលទៅក្នុងបានឡើយ!»

ព្រះអង្គក្រោកឈរឡើងហើយរំពៃសម្លឹងបណ្តាតំណក់ទឹកដែលជ្រៀតមកបានគ្រប់ទីកន្លែង ប្រៀបបីដូចជាតំណក់ទឹកភ្នែកនៃមនុស្សស្រីអតីតកាលក្នុងទ័យាដែលទ្រង់មិនអាចទតឃើញតែបេះដូងទទួលដឹង។

សំឡេងដដែលពោលបន្តថា៖

«មិនត្រាវ៉ាវីនេះគឺជាគ្រូមន្តអាគមខ្មៅ! នាងតែងតែច្រណែនជាមួយស្នេហាយើង! នៅពេលមួយពេលដែលព្រះចៅអធិរាជចេញទៅធ្វើសង្គ្រាម នាងបានរួមដៃជាមួយម្តាយចុងខ្ញុំក្នុងការល្បួងហៅខ្ញុំឱ្យត្រឡប់ទៅលេងផ្ទះ! នៅពេលដែលខ្ញុំទៅដល់ផ្ទះកាលណា ពួកគេបានរួមដៃគ្នាចាប់បង្ខំខ្ញុំទម្លាក់ទឹកក្នុងអាងទឹកមួយ ហើយសេពមន្តអាគមដ៏កំណាចឃោរឃៅធ្វើឱ្យរាងកាយរបស់ខ្ញុំរលាយទៅជាទឹកភ្លាមៗ ខ្លួនវាបានប្រែក្លាយទៅជារូបរាងខ្ញុំ និងហៅខ្លួនឯងថាជាសាវ៉ាឌី ទៅរួមរស់ជាមួយស្វាមីពេលទ្រង់វិលពីសមរភូមិមុខត្រឡប់មកវាំងវិញ! ដោយការឈឺចាប់ នៅមុនពេលស្លាប់ខ្ញុំបានស្បថស្បែឡើងថា នឹងចងគំនុំជាមួយស្រីបិសាចនេះ ជានិច្ចអស់កប្ប! ទោះបីក្លាយទៅជាអ្វី វានឹងមានភ្លើងនៅប្រជុំចិញ្ចើមដែលធ្វើឲ្យខ្ញុំចំណាំបានគ្រប់ពេលវេលាដែលភ្លើងឆេះសន្ធោសន្ធៅ នាងនឹងត្រូវសងនូវអ្វីម្យ៉ាងដែលបានជំពាក់មកកាន់ខ្ញុំ!»

ស្តេចភ្ញាក់ព្រើតនឹកឃើញរឿងចាស់ឡើងថា នៅពេលដែលព្រះអង្គយាងត្រឡប់មកដល់រាជវាំង រួមរស់ជាមួយនាងមិនត្រាវ៉ាវី ទាំងមិនដឹងថានាងគឺជាមនុស្សក្លែងក្លាយជាសាវ៉ាឌីនោះទេ រហូតនៅយប់មួយព្រលឹងទឹក នឹករលឹកទ្រង់ជាស្វាមីសម្លាញ់ខ្លាំងពេក ក៏បានជ្រៀតតាមរយៈតំណក់ទឹកតូចៗចូលទៅជួបជាមួយស្វាមីក្នុងទីត្រាំសម្អាតកាយ។

គ្រានោះទាំងពីរបានមានក្តីសុខរួមរស់ជាមួយគ្នានៅក្នុងអាងទឹករាជវាំងយ៉ាងស្ងាត់កំបាំងឥតអ្នកណាយល់។ អំណើះតមក ស្វាមីក៏លង់តែជាមួយទឹកក្រសាលអង្គ លែងមានស្នេហាឬទៅរវល់ជាមួយនាងមិនត្រាវ៉ាវីដែលក្លែងកាយទេ ទ្រង់តែងតែសំងំទៅងូតទឹកម្នាក់ឯងនៅក្នុងរាជវាំងដោយចិត្តស្មោះស្ម័គ្រចំពោះអតីតភរិយាជាតំណក់ទឹក។

«រយៈពេលនោះ នាងមិនត្រាវ៉ាវីដែលកើតចិត្តអផ្សុកនិងឫស្យាបានមានសាហាយស្មន់ជាច្រើនថែមទាំងបង្កើតបាននូវរឿងរ៉ាវអាស្រូវក្នុងឈ្មោះរូបកាយយើង ធ្វើឲ្យយើងនេះត្រូវបានប្រជារាស្ត្រស្អប់ខ្ពើម ពួកមន្ត្រីនិយាយថ្កោលទោស»

ក្រោយមកទៀតព្រះអង្គបានមានការខូចចិត្តជាខ្លាំង ទ្រង់ក៏បានចូលទៅក្នុងអាងហើយសំងំត្រាំខ្លួនជាមួយនឹងភរិយា ប្រឹងអត់ដង្ហើមខ្លួនឯងរហូតទាល់តែក្ស័យព្រះជន្មនៅក្នុងគ្រានោះលាចាកពីវិបត្តិផងទាំងពួង។

ដោយសារតែខ្ញុំជាទឹក មានកម្មព្រោះដែមនុស្សជួរជាតិ មិនចេះនិយាយនិងមិនអាចប្រាប់ឲ្យដឹងពីហេតុការណ៍ពិត ប៉ុន្តែព្រះអង្គនៅតែមិនដឹងរឿងទាំងឡាយ អស់ពាន់ឆ្នាំមកហើយ។

ព្រះអង្គបានស្បថនៅចងចាំខ្ញុំមិនព្រមទៅចាប់ជាតិនៅឯណានៅក្នុងរាជដំណាក់ចាស់ប៉ុន្តែប្រពន្ធបានក្លាយទៅជាទឹក ហើយប្រពន្ធមិនអាចទៅរកបងបានទេ រហូតដល់ច្រើនជាតិកន្លងមកនេះមនុស្សស្រីឃោរឃៅបានចាប់កំណើតហើយដាក់ឈ្មោះជាច្រើនយ៉ាង នាងនៅតែមានភ្លើងលើកញុំចិញ្ចើម ។

«លើកនេះនាងបានទៅរកព្រះអង្គដល់អតីតរាជវាំងដដែលជាដដែល ពេលនោះខ្ញុំកើតចិត្តសៅហ្មងជាខ្លាំង និងបានព្យាយាមធ្វើជាកម្លាំងទឹកមកពន្លិចនាងនៅក្នុងផ្ទះនេះប៉ុន្តែព្រះអង្គបានចេញមុខមកទាន់ពេលវេលាដែលបានធ្វើឱ្យទឹកក្លាយទៅជាសម្លួតហើយខ្ញុំមិនអាចធ្វើបាបនាងបាននឹងព្រះភក្ត្រទ្រង់ ព្រោះខ្ញុំចង់ប្រាប់ព្រះអង្គរឿងការពិតទាំងអស់នោះថា នាងតាមពិតបានប្រើមន្តអាគមបន្លំខ្លួនជាហេតុដែលមិនអាចចូលទៅប្រាង្គប្រាសាទអតីតបាន។»

ឮរឿងនេះហើយ មេរូបានកើតភាន់ភាំងជាខ្លាំង។ ចំណែកស្តេចនៅស្រងូតនិងក៏មិនដឹងថាត្រូវធ្វើយ៉ាងណានោះដែរ។ ភ្លាមនោះមេរូបានស្រែកតវ៉ាថា៖

«នែបិសាចទឹក បើហ៊ានមកចោទថាខ្ញុំមិនមែនជានារីដ៏កម្សត់នោះ ហើយអ្នកថាអ្នកជានារីសាវ៉ាឌី ពិតក៏គួរមានអ្វីជាភស្តុតាងទេ?»

ទឹកតបឆ្លើយវិញថា៖

«ដូច្នេះចូរនាងកាត់សក់របស់នាង ៨ សរសៃហើយបង់វាទៅក្នុងខ្យល់ ជាមួយពាក្យស្បថថាសូមអំពើអាក្រក់ៗទាំងអស់សត្វលោក និងមន្តអាគមទាំងអស់ដែលនាងធ្លាប់ធ្វើទៅលើសត្វលោកក្លាយទៅជាអាសារ នោះយើងនឹងក្លាយទៅជារូបពិត!»

មេរូគិតចុះឡើងទាំងខ្វល់ខ្វាយ។ នាងស្រក់ទឹកភ្នែកសម្លឹងទៅស្វាមីសម្លាញ់របស់នាងចិត្តមួយៗនិងគិតថាបើសិនជាអ្វីដែលតំណក់ទឹកបាននិយាយតំណាលជាការពិត ម្ល៉េះសមនាងនឹងត្រូវបែកពីបុរសជាទីស្រឡាញ់គ្នាជារៀងរហូតមិនខាន។

«ចុះបើយើងមិនព្រមធ្វើតាមបង្គាប់នាង នាងនឹងបង្កើតជាតំណក់ទឹកលិចលង់នៅក្នុងផែនដីនេះទាំងមូលដោយសារតែកំហឹងស្នេហាចាស់របស់នាងឬយ៉ាងណា?»

ទឹកតបឆ្លើយ៖

«នេះបង្ហាញថាទោះជាតិណាក្តី រាប់ពាន់ឆ្នាំមកហើយ នាងនៅតែជាមនុស្សមានភាពមិនស្មោះត្រង់ចំពោះស្នេហា! ដូចមានការពីអតីតជាតិដែលតែងតែជាមនុស្សអាក្រក់ អាត្មានិយម!»

មេរូយំជាខ្លាំងហើយស្រែកឡើងថា៖

«តែបើយើងមិនមែនចិត្តអាក្រក់ដូចក្នុងរឿងដំណើររបស់អ្នកនិទានទេ ដូច្នេះពេលយើងធ្វើតាមអ្នកប្រាប់ អាចទេជាវិធីដែលអ្នកធ្វើឱ្យយើងក្ស័យសូន្យទៅលែងបានជួបជាមួយប្រុសស្នេហ៍របស់យើង?!»

ទឹកស្រែកឡើងថា ៖

«យើងសូមប្រើថាមពលទឹកនិងដីមកស្បថសច្ចាថា ដោយសារយើងគឺជាអ្នកដែលមានកម្មជាច្រើនសតវត្សមកហើយ យើងនឹងមិននិយាយកុហក នឹងមិនធ្វើឲ្យខ្លួនយើងជាប់វេនវេរាទៀតនោះទេ។»

មេរូសុខចិត្តកាត់សក់៨សរសៃនិងបណ្តែតទៅក្នុងខ្យល់ ហើយគ្រាន់តែនិយាយឡើងថា សូមឲ្យការពិតទាំងអស់ចេញមកសាបរលាបអំពើអាក្រក់ទាំងអស់ និងមន្តគាថានានាកាលពីអតីតជាតិប្រសិនសម្តីតំណក់ទឹកទាំងនេះជារឿងពិតមែន។

អស្ចារ្យខ្លាំងណាស់ គ្រាន់តែមេរូធ្វើហើយភ្លាម ទឹកបានហួតវិលចូលគ្នា ពូនផ្តុំទៅជារូបរាងមនុស្សស្រី ហើយប្រែក្លាយទៅជារូបរាងបេះបិទនឹងមេរូនាបច្ចុប្បន្ននេះប៉ុន្តែក្នុងសំលៀកបំពាក់ទ្រង់គ្រឿងជាបុរាណដ៏ស្រស់ប្រណីត មានសក់វែងអន្លាយដល់កំភួនជើងទៅទៀត។

ដៃនាងមានពាក់ចិញ្ចៀនគ្រប់ម្រាម លំដាប់ជាជាក្សត្រីនៃរាជនគរដ៏រុងរឿងមួយ។ គ្រាន់តែស្តេចទតឃើញកាណាចាប់ផ្តើមទន់ចិន្តា ហើយបែរទៅសួរថា៖

«បើព្រះនាងគឺជាព្រះមហេសីរបស់យើងសាវ៉ាឌី នាងព្រមទៅតាមយើងដែរទេជាកិច្ចបញ្ជាក់ការពិតឱ្យបានដឹងនៅនឹងអតីតរាជវាំង?!»

នារីនោះស្រក់ទឹកភ្នែកជំនួសឲ្យចម្លើយ ហើយពួកគេចាកចេញទៅ។ មេរូបានឃើញអ្នកទាំងពីរហោះទៅក្នុងអាកាសសំដៅទៅកាន់ប្រាសាទ។

នាងដួលសន្លប់ ចាប់ផ្តើមយល់សប្តិថា នាងខំប្រឹងដើរតាមពួកគេទៅដល់ប្រាសាទបុរាណ ហើយឃើញ ទិព្វអង្គទាំងពីរប្រាណប្រើប្រាមដៃរបស់ពួកគេ បញ្ជាមន្តបើកទ្វារប្រាសាទបាន ដោយមិនពិបាកអ្វី ថែមអាចបណ្តែតព្រះកាយទ្វេចូលទៅក្នុងប្រាសាទនោះបាត់ឈឹង។

នេះមិនដូចកាលដែលប្តីនាងខំនាំនាងទៅយ៉ាងណាក៏នៅតែមិនអាចទៅរួចព្រោះជញ្ជាំងថ្ម ចូលបានតែខាងប្រុស យើងនេះមិនមែនជាតួស្រីពិតប្រាកដនៅក្នុងអតីតរាជវាំងទេ។

នៅថ្ងៃស្អែកឡើងមេរូបានដឹងខ្លួន ឃើញខ្លួនឯងនៅក្នុងគ្រែពេទ្យជាមួយម្តាយនិងបងប្រុស ឈ្មោះមីន។

«ហើយឯងទៅប្រសាទនោះធ្វើអ្វីម្នាក់ឯងទាំងកណ្តាលយប់ស្ងាត់ មិនហៅបងទៅដែរ?»

ត្រូវបងប្រុសសួរនាំ មេរូបានត្រឹមតូចចិត្តនាងយំម្នាក់ឯង មិននិយាយស្តីអ្វីនៃអាថ៌កំបាំង អស់ទាំងនោះប្រាប់នរណាឡើង។ ក្នុងចិត្តនាងបានប្តូងសួងចង់បំភ្លេចរឿងរ៉ាវទាំងអស់ចោល ចេញប៉ុន្តែគ្រប់យ៉ាងម៉េចមិនអាចភ្លេចបានជានិច្ចជាកាល។

មេរូស្នាក់នៅព្យាបាលក្នុងមន្ទីរពេទ្យយូរណាស់ដោយសារតែនាងមិននិយាយ មិនស្តី និង មិនចង់ហូបអ្វីទាំងអស់។

ថ្ងៃមួយម្តាយនាងរកតាបសម្នាក់ ជាហិណ្ឌូមានជំនាញផ្លូវមន្តអាគមជ្រាលជ្រៅ។ តានោះ បាននៅសួរនាំនាង នាងក៏ប្រាប់រាល់ដំណើររឿង ហើយបាននិយាយផងដែរអំពីសេចក្តីប្រាថ្នា ក្នុងពេលនេះគ្មានអ្វីជាងការបំភ្លេចអតីតកាល ក្លាយទៅជាអ្នកដែលមិនដឹងរឿងអ្វីទាំងអស់កាល ពីមុន ដើម្បីអាចរស់នៅបានស្រស់ស្រាយឡើងវិញសាជាថ្មី។

ក្រោយពីយល់រឿងហើយតាបសបានភាវនារកហេតុនិងភេទមកជួសជុលស្ថានការណ៍ឱ្យ។ ពេលដឹងខ្លួនមកវិញ តាប្រាប់មេរូថា៖

«នាងមិនអាចភ្លេចឬធូរស្បើយចិត្តបាន ព្រោះជតានៅមានជាប់កម្មពៀរដែលបានបំបែកពួកគេ ដូច្នេះនាងនឹងត្រូវរស់នៅដោយឈឺចាប់ដូច្នេះគ្រប់ជាតិរហូតទាល់តែនាងសងអស់នូវបាបកម្ម ទាំងឡាយ!»

ថ្ងៃនោះហើយមេរូព្រមវិលមកផ្ទះ។

យប់ឡើងស្ងាត់នាងបានស្រែកហៅក្នុងចិត្តថា ឱ! អធិរាជភ្នែកត្បូង ខ្ញុំក៏ជាប្រពន្ធម្នាក់របស់ អ្នកទាំងនោះ តើអ្នកមកជួបខ្ញុំបានទេ។

ស្តេចខ្មៅបានបង្ហាញខ្លួនជាមួយកែវភ្នែកជាគ្រាប់ត្បូង នាងសួរឡើងថា ហេតុអីបានជាពេលនេះខ្ញុំនៅឆ្ងាយពីអ្នកខ្ញុំឈឺចាប់ខ្លាំង ហើយនៅពេលដែលអ្នកមកដល់ខ្ញុំកាន់តែក្រហល់ក្រហាយត្រង់ថ្ងាស?

ស្តេចឆ្លើយថា៖

«វាជាផលកម្មពៀរជ្រាលជ្រៅដែលនាងបានសាងពីអតីត! តែយើងគឺជាប្តីម្នាក់របស់នាងដែរ ទោះតែចិត្តយើងមិនបានស្រឡាញ់នាង ប៉ុន្តែយើងនឹងជួយសម្រាលទុក្ខរបស់នាងខ្លះបាន!»

ថាហើយស្រមោលខ្មៅក៏បានខំស្រក់មកនូវទឹកភ្នែកជាច្រើនតំណក់ដែលក្លាយជាគ្រាប់ត្បូង និងប្រគល់ត្បូងទាំងឡាយនោះឲ្យមេរូដោយប្រាប់ផ្តាំថា៖

«នៅរាល់ពេលដែលនាងឈឺចាប់ដោយរង្វង់ភ្លើងកម្មនៅលើប្រជុំថ្ងាស នាងអាចលេបត្បូងមួយចូលទៅក្នុងពោះ ហើយកម្តៅទាំងអស់នឹងរលាយបាត់សូន្យបាន! តែត្រូវចាំថាពេលនាងប្រើវាម្តង ភ្នែកយើងនឹងព្រិលរកាំអស់រស្មីបន្តិច ក្រោយៗទៀតបើយើងនៅតែឱ្យទឹកភ្នែកទៅនាងលេប  ថ្ងៃណាមួយយើងនឹងត្រូវខ្វាក់ភ្នែកទាំងសងខាងបាន!»

ស្តេចបានរលាយទៅបាត់ បន្សល់ឱ្យមេរូនូវបណ្តាគ្រាប់ត្បូងក្នុងដៃ ដែលនាងពិតជាឈឺចាប់ខ្លាំងស្រែកហៅព្រះរៀមរហូតទាល់តែហត់នឿយស្អកក ក៏មិនឃើញទ្រង់បង្ហាញកាយឡើយ។

ពីមួយពេលទៅមួយពេល មេរូរមែងផ្តើមនឹកដល់ព្រះអង្គជាខ្លាំងឡើងៗ ប៉ុន្តែនាងមិនហៅរកអង្គប្រាណ មកទៀតទេដោយយំយែកនិយាយថា យើងមានបាបកម្មជាច្រើនចំពោះព្រះអង្គនៃត្បូងខៀវ ដូច្នេះយើងមិនចង់ឲ្យព្រះអង្គបរិច្ចាគទឹកភ្នែករបស់ទ្រង់មកឱ្យយើងឡើយ។

សូមមេឃដីជួយដឹងឮ យើងព្រមសងកម្មទាំងអស់របស់មិនត្រារ៉ាវីដោយមិនគេចវេះឬទោមនស្សអ្វី។

ថាហើយនាងបានបោះគ្រាប់ត្បូងទាំងអស់ដែលជាអនុស្សាវរស្នេហ៍ចុងក្រោយ ចោលទៅក្នុងខ្យល់ធ្លាក់ទៅជាន់ក្រោមជ្រៅសន្លឹមតាមបង្អួចនេះ តាំងចិត្តថាបើសិននេះគឺជាបាបកម្មរបស់នាងដែលបានធ្វើចំពោះប្តីប្រពន្ធទាំងពីរកាលពីអតីត ទោះឆ្នាំកន្លងទៅយូរប៉ុនណានាងសុខចិត្តស្ម័គ្ររស់នៅក្រៀមក្រំចង់ចាំនូវរឿងទាំងអស់នេះ ហើយសងជាបន្តបន្ទាប់ ដល់អស់ពេលវេលានៃជីវិតរបស់នាង។

មេរូបានចេញមកក្នុងសង្គមឡើងវិញនិងសរសេរសៀវភៅមួយដែលមានចំណងជើងថា«កុំធ្វើអំពើអាក្រក់» នាងបានពណ៌នាថា ពីព្រោះអ្នកមិនអាចគេចវេះមិនសងវានោះឡើយ! ហើយខ្ញុំនឹងសងបំណុលទាំងអស់នេះ ជាបន្តបន្ទាប់ដោយរស់នៅឯកោម្នាក់ឯងដូច្នេះតទៅ។

ពេលនោះដែរស្រាប់តែនាងសុបិនឆ្អែកស្រស់អំពីរឿងដែលគួរឲភ័យព្រួយមួយទៀត គឺឃើញខ្លួនឯងមិនមែនមុខមាត់បែបនេះ គឺជានារីម្នាក់មានពាក់ម៉ុដជាមួយទឹកមុខកាចសាហាវច្រណែនឫស្យាសក់វែងអន្លាយ។

មេរូដឹងភ្លាមថានេះជារូបពិតកាលពីមិនទាន់បម្លែងខ្លួនបន្លំទៅនឹងភរិយារបស់ទ្រង់ជារូបរបស់មិនត្រាវ៉ារី។ នៅក្នុងសុបិនមេរូបានឃើញខ្លួនឯងកំពុងតែដើរទៅឱបប្រាសាទថ្ម ហើយស្រែកហៅឮៗនៅក្នុងជាតិប៉ុន្មានមុនៗថា «ព្រះអង្គអើយតើអ្នកឮខ្ញុំនិយាយទេ ខ្ញុំជាមិនត្រាវ៉ារី ហេតុអ្វីអ្នកមិនចេញមករកខ្ញុំ ហេតុអ្វីអ្នកមិនមកនាំប្រពន្ធចូលទៅកាន់ប្រាសាទចាស់ និងជញ្ជាំងថ្មកំណាចដែលឃារខណ្ឌយើង!»

ជញ្ជាំងថ្មដែលរឹងដូចពេជ្រ និងថ្លាដូចកញ្ចក់បានត្រឹមឆ្លើយឡើងថានាងមិនត្រូវទៅទីនេះ

មានៈយំសោកទេ ព្រោះនាងហ្នឹងមិនមែនជាប្រពន្ធរបស់យើងជារៀងរហូតទៅ!

ដូច្នេះហើយមិនត្រាវ៉ារីនៅក្នុងជំនាន់នោះ បានឱបជញ្ជាំងយំសស្រាក់ជានិច្ចថែមទាំងនិយាយឆ្កួតវង្វេងតែម្នាក់ឯងរហូតដល់ក្ស័យព្រះជន្ម។

ដឹងខ្លួនពីព្រឹត្តិការណ៍អតីតទាំងអស់នោះហើយ មេរូកាន់តែត្រូវខ្លោចផ្សាយ៉ាងខ្លាំង។ នាងដឹងហើយថាសេចក្តីស្នេហាអាត្មានិយម និងការលោភលន់ ការក្លែងបន្លំទោះបីប៉ុន្មានជាតិនៅតែត្រូវរងនៅក្នុងកម្មពៀរមិនចេះចប់មកទល់ពេលនេះ។

នាងបានសម្រេចចិត្តទៅបួសរៀននៅវិហារមួយដែលមានសុទ្ធតែដូនជី នៃព្រះពុទ្ធសាសនា។ ព្រះអធិការបានប្រាប់នាងថាព្រះជាអ្នកបង្កើតអ្វីៗទាំងអស់លើផែនដីយើង ទ្រង់ថែមបានដាក់ចេញនូវច្បាប់ដែលមនុស្សត្រូវរស់នៅ ដើម្បីបានសេចក្តីសុខ បានសម្រេច និងគាប់ព្រះហឫទ័យព្រះជាម្ចាស់។ អំពើបាបគឺជាការបះបោរប្រឆាំងនឹងព្រះ ក៏ដូចជាការតវ៉ាលើការគ្រប់គ្រងរបស់ទ្រង់។

ជាអកុសលសម្រាប់មនុស្សជាច្រើន បានព្រងើយកន្តើយនឹងសតិសម្បជញ្ញៈហើយលង់ទៅក្នុងតណ្ហា រកឧបាយកលមកបំពេញតែចិត្តខ្លួនឯងអស់រយៈពេលជាយូរណាស់មកហើយ ដែលធ្វើឲ្យពួកគេពិបាកក្នុងការស្វែងយល់ពីអត្ថន័យពិតនៃអ្វីដែលហៅថាត្រូវ និងខុស។

ពេលអ្នកធ្វើដូច្នេះ អ្នកនឹងស្តាប់បង្គាប់ព្រះ ហើយមិនមែនជាឈ្លើយនៃអំពើបាបឡើយ។

ព្រះវិញ្ញាណបរិសុទ្ធមានតួនាទីជាច្រើន ពោលគឺការបង្រៀន ដឹកនាំយើងឱ្យយល់ការពិត ចងចាំរឿងដែលយើងបានរៀនពីជីវិតនិងទង្វើកម្មនៃយើងខ្លួនឯង។ល។ ព្រះនឹងកាត់ទោសពិភពលោកអំពីមនុស្សមានអំពើបាប ខ្វះសេចក្តីសុចរិត និងការវិនិច្ឆ័យដោយធ្វើឱ្យយើងមានអារម្មណ៍មិនស្រួលចំពោះអ្វីដែលយើងបានធ្វើ ប្រសិនមិនខំប្រព្រឹត្តិល្អកែខ្លួន ជាកិច្ចសុំការអភ័យទោស សម្អាតពីអំពើបាប  យើងនឹងឈប់រីកចម្រើន មានអារម្មណ៍ថាមានកំហុសដែលមិនអាចដោះស្រាយរហូតថ្ងៃស្លាប់។ អារម្មណ៍ខុសឆ្គងនៃកំហុស ដែលអាចបណ្តាលឱ្យយើងមិនរីកចម្រើនក្នុង វិញ្ញាណរស់នៅក្នុងរបៀបដែលពិបាកបំភ្លេចចោលជារៀងរហូត។

កាត់បន្ថយអំពើបាប និងព្យាយាមដើរឆ្លងឱ្យស្មោះអស់ពីចិត្តឡើង។